ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# សុន្ទរកថា

## លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសិក្ខាសាលាស្តីពីប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ

នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤

**សូមគោរព ៖**

– លោក Christie Richards អ្នកជំនាញអន្តរជាតិផ្នែកស្ថិតិរបស់លេខាធិការដ្ឋានអាស៊ាន
– លោក តាន់ សុខាន់ ប្រធាននាយកដ្ឋានស្ថិតិ
– លោក លោកស្រី និងនាងកញ្ញាទាំងអស់ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានមកចូលរួមសិក្ខាសាលាស្តីពីប្រព័ន្ធរបាយ-ការណ៍ប្រតិបត្តិការអន្តរជាតិ (International Transactions Reporting System = ITRS) ។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងដើម្បីផ្តល់កិច្ចពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នា ក្នុងការចងក្រងប្រព័ន្ធរបាយការណ៍ ITRS ឲ្យកាន់តែប្រសើរឡើងថែមទៀត ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោក លោកស្រី និងនាងកញ្ញាទាំងអស់ដែលបានចូលរួមក្នុងសិក្ខាសាលានេះ ។

ប្រព័ន្ធរបាយការណ៍ ITRS នេះ បានដាក់ឲ្យដំណើរការនៅធនាគារជាតិនៃកម្ពុជា ចាប់តាំងពីខែមករា ឆ្នាំ២០០៣ មក ។ ក្នុងខែតុលា ឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជា បានរៀបចំកិច្ចប្រជុំណែនាំ និងពិភាក្សាការងារពាក់ព័ន្ធនឹងការរាយការណ៍អំពីប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) ផ្អែកតាមសៀវភៅ " វិធីសាស្ត្រណែនាំអំពីការធ្វើចំណាត់ថ្នាក់និងនីតិវិធីចងក្រងប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិសម្រាប់វិស័យធនាគារកម្ពុជា " ថ្មី ដែលត្រូវបានរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា ជាភាសាខ្មែរ និងភាសាអង់គ្លេស ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដល់ថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិក នៃនាយកដ្ឋានស្ថិតិ នៃធនាគារជាតិនៃកម្ពុជា និងមន្ត្រីជំនាញទទួលបន្ទុកចងក្រងរបាយការណ៍ ITRS ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការពង្រឹងគុណភាពនៃរបាយការណ៍ ITRS ។ លើសពីនេះ ការងារ ITRS ក៏តម្រូវឲ្យមានការខិតខំយកចិត្តទុកដាក់ និងការចូលរួមយ៉ាងសកម្មផងដែរ ពីអ្នកចងក្រងរបាយការណ៍ ITRS របស់ធនាគារពាណិជ្ជ និងមន្ត្រីទទួលបន្ទុក ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ សំដៅធ្វើយ៉ាងណាកុំឲ្យ

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

មានកំហុសឆ្គងនៅក្នុងការចងក្រងរបាយការណ៍ ITRS ផ្ញើមកធនាគារជាតិនៃកម្ពុជា ។ សិក្ខាសាលាក្នុងថ្ងៃនេះ នឹងផ្តល់ឱកាសមួយយ៉ាងសំខាន់ដល់អ្នកចងក្រងរបាយការណ៍ ITRS និងអ្នកពាក់ព័ន្ធទាំងអស់ អាចបញ្ចេញមតិយោបល់ និងស្វែងរកនូវដំណោះស្រាយរួមគ្នា ដើម្បីពង្រឹងគុណភាពចងក្រងប្រព័ន្ធរបាយការណ៍ ITRS ឲ្យកាន់តែសុក្រឹត្យ ទាន់ពេលវេលា និងអាចយកទៅប្រើប្រាស់ក្នុងស្ថិតិជញ្ជីងទូទាត់កម្ពុជាបានកាន់តែទូលំទូលាយថែមទៀត ។

ខ្ញុំសូមបញ្ជាក់ថា ITRS ជាប្រភពទិន្នន័យចម្បងមួយក្នុងចំណោមប្រភពទិន្នន័យផ្សេងទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ការចងក្រងស្ថិតិជញ្ជីងទូទាត់ប្រទេសកម្ពុជា ។ ដោយសារតែរាល់ប្រតិបត្តិការអន្តរជាតិត្រូវបានធ្វើឡើងតាមប្រព័ន្ធធនាគារ និងដែលត្រូវបានបង្ហាញក្នុងស្ថិតិជញ្ជីងទូទាត់ ដូច្នេះស្ថិតិនេះបានដើរតួនាទីដ៏សំខាន់ក្នុងដំណើរការកំណត់គោលនយោបាយសេដ្ឋកិច្ច រៀបចំផែនការយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់ជាតិ និងអន្តរជាតិ ដូចជា ការរៀបចំកម្មវិធី និងគោលនយោបាយហិរញ្ញវត្ថុ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច ការកំណត់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិនានា ។ ទិន្នន័យទាំងនេះក៏ត្រូវបានប្រើប្រាស់ក្នុងការសិក្សាវិភាគលើប្រធានបទមួយចំនួនផងដែរ គឺ (១) ការកំណត់ពីបុព្វហេតុនៃអតុល្យភាពនៃការទូទាត់ ដើម្បីកែតម្រូវនយោបាយដែលកំពុងអនុវត្ត (២) ការបង្ហាញពីទំនាក់ទំនងរវាងពាណិជ្ជកម្មទំនិញ និងការវិនិយោគផ្ទាល់ (៣) ពាណិជ្ជកម្មអន្តរជាតិផ្នែកសេវាកម្ម (៤) ឥទ្ធិពលនៃលំហូរវិនិយោគ (៥) បញ្ហាបំណុលបរទេស និង (៦) ទំនាក់ទំនងរវាងអត្រាប្តូរប្រាក់និងលំហូរនៃគណនីចរន្ត និងគណនីហិរញ្ញវត្ថុ ។ល។ លើសពីនេះ ទិន្នន័យវិស័យក្រៅប្រទេស (External Sector) នេះ ត្រូវបានប្រើប្រាស់ជាមួយនឹងទិន្នន័យអថេរសេដ្ឋកិច្ចផ្សេងទៀត ដើម្បីព្យាករប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងជាមួយនឹងបម្រែបម្រួលនៃទ្រព្យសកម្មនិងទ្រព្យអកម្មបរទេសនៃសេដ្ឋកិច្ច ។

ខ្ញុំសង្ឃឹមថា បន្ទាប់ពីសិក្ខាសាលានេះ អ្នកចងក្រងរបាយការណ៍ ITRS អាចនឹងស្វែងយល់បន្ថែមទៀត និងអាចបញ្ចៀសនូវកំហុសឆ្គងជាអតិបរមាដែលធ្លាប់មានកន្លងមក ។ ខ្ញុំសូមជម្រាបថា ធនាគារជាតិនៃកម្ពុជា នឹងរៀបចំ*លិខិតជូនដំណឹង* ផ្ញើជូននាយក នាយិកា គ្រប់គ្រងនៃធនាគារពាណិជ្ជ និងអ្នកពាក់ព័ន្ធទាំងអស់ ប្រសិនបើកំហុសដដែលៗនៅតែកើតមានឡើងម្តងហើយម្តងទៀតនាពេលអនាគត ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរសិក្ខាកាមតំណាងមកពីធនាគារពាណិជ្ជទាំងអស់ មន្ត្រីជំនាញមកពីនាយកដ្ឋានស្ថិតិ មន្ត្រីជំនាញមកពីបណ្តានាយកដ្ឋាន ចំណុះអគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានព័ត៌មានវិទ្យា និងអគ្គនាយកដ្ឋានត្រួតពិនិត្យ ដែលមានវត្តមាននៅក្នុងសិក្ខាសាលានេះ ជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឲ្យសិក្ខាសាលាដែលនឹងប្រព្រឹត្តទៅរយៈពេល ០១ថ្ងៃ នេះ ដំណើរការដោយជោគជ័យ ។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាស្តីពីប្រព័ន្ធរបាយការណ៍ ITRS ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ !**